# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផល ទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជា

Downloaded from http://www.khmerlaws.com

អគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.—**

អនុក្រឹត្យនេះ កំណត់អំពីប្រភេទផល ផលិតផលជលផលទឹកសាបនិងសមុទ្រដែលមានប្រភពចេញពីធនធានជលផលកំពុងរងគ្រោះថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារ គ្រប់គ្រង និងអភិរក្សឱ្យមាននិរន្តរភាព ស្របតាមច្បាប់ស្តីពីជលផល។

## ជំពូកទី២

## ចំណាត់ថ្នាក់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

**មាត្រា២.—**

ប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់ ត្រូវបានចាត់ថ្នាក់ជាបីក្រុមទៅតាមលក្ខខណ្ឌនិងស្ថានភាពនៃភាពកំពុងរងគ្រោះដូចខាងក្រោម ÷

១. ក្រុមប្រភេទជិតផុតពូជ : ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះថ្នាក់ ដែលចំពោះមុខជលស្តុកក្រុមប្រភេទនេះកំពុងប្រឈមទៅនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ហើយអាចវិនាសផុតពូជទាំងស្រុងនៅក្នុងធម្មជាតិនាពេលអនាគតដ៏ខ្លីខាងមុខ ដោយបរិមាណសរុបបានថយចុះយ៉ាងតិច៨០ (ប៉ែតសិប) ភាគរយ ក្នុងរយៈពេល១០ (ដប់) ឆ្នាំ ចុងក្រោយឬក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមក តាមរយៈការអង្កេត ការប៉ាន់ប្រមាណ ឬ ការសន្និដ្ឋាន។

២. ក្រុមប្រភេទកំពុងរងគ្រោះ : ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះថ្នាក់ ដែលមានភស្តុតាងបង្ហាញច្បាស់ថា ក្រុមប្រភេទនេះកំពុងប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតមិនយូរប៉ុន្មាន ដោយបរិមាណសរុបបានថយចុះយ៉ាងតិច៥០ (ហាសិប) ភាគរយ ក្នុងរយៈពេល១០ (ដប់) ឆ្នាំ ចុងក្រោយ ឬក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមក តាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋាន ឬការរំពឹងទុក។

៣. ក្រុមប្រភេទងាយរងគ្រោះ : ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះ ដែលងាយប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតខាងមុខ ដោយបរិមាណសរុបបានថយចុះយ៉ាងតិច២០ (ម្ភៃ) ភាគរយ ក្នុងរយៈពេល

Downloaded from http://www.khmerlaws.com

១០ (ដប់) ឆ្នាំចុងក្រោយឬរយៈពេលបីជំនាន់តំណពូជកន្លងមក តាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋានឬការរំពឹងទុក ។

**មាត្រា៣.–**

ចំណាត់ថ្នាក់ប្រភេទធនធានជលផលមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៤.–**

ការកែសម្រួល និងការកំណត់បន្ថែមអំពីប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ទៅអនាគត ត្រូវកំណត់ដោយអនុក្រឹត្យ ។

វិធានការការពារប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៥.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្តពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ១២៣ .អនក្រ.បក ចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកំណត់ប្រភេទផល ផលិតផលដែលកំពុងរងគ្រោះថ្នាក់

## តារាងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

| ល.រ | រូបភាព | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | ឧបសម្ព័ន្ធ សាយតេស | ចំណុចសំខាន់ៗ |
|---|---|---|---|---|---|---|
| **ក. ទឹកសាប** | | | | | | |
| **ក្រុមប្រភេទជិតផុតពូជ** | | | | | | |
| ១ |  | ត្រីតាពត ឬ ត្រីនាគ | *Scleropages formosus* | Asian bonytongue | I | - រស់ និងពងកូននៅតាមបណ្តាជ្រោះមួយចំនួននៃតំបន់ជួរភ្នំក្រវាញបែកខាងត្បូងដល់កំពត<br>- ស៊ីត្រី និងសត្វល្អិតជាអាហារ<br>- អាយុ ៣-៤ ឆ្នាំ អាចបន្តពូជបាន<br>- ពងមិនលើស ២០-៤០ គ្រាប់ ចំពោះមេមួយក្បាល<br>- ប្រវែងវែងបំផុត ៩០ ស.ម ។ |
| ២ |  | ត្រីថ្ក | *Pristis microdon* | Sawfish | I | - ជាប្រភេទរស់នៅស្រទាប់ភក់ស្តើងនៃបាតទន្លេ មាត់ពាម និងតំបន់ទឹកដែលមានកំហាប់អំបិលតិច<br>- ស៊ីពពួកត្រី និងសត្វឥតឆ្អឹងកងស្រទាប់បាត<br>- រដូវពងកូននៅចន្លោះខែវិច្ឆិកា-ធ្នូ<br>- ប្រវែងវែងបំផុត ៦០០ ស.ម ។ |
| ៣ |  | ត្រីបីកំណាត់ ឬ ត្រីខ្លា | *Puntius partipentazona* | Tiger barb | | - រស់នៅស្រទាប់ទឹកកណ្តាល និងបាតនៃស្ទឹង ទន្លេ បឹងទន្លេសាប និងតំបន់មេគង្គក្រោម<br>- ស៊ីពពួកសត្វល្អិត និងបន្លែគុងសត្វ<br>- បន្តពូជក្នុងតំបន់រុក្ខជាតិលិចទឹក ដោយពងតោង |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ជាប់នឹងរុក្ខជាតិ<br>- ប្រវែងវែងបំផុត ៩ ស.ម ។ |
| ៤ |  | ត្រីក្រៀតស្រង់ | *Balantiocheilos melanopterus* | Bala sharkminnow | | - រស់តាមទន្លេ និងព្រៃលិចទឹកបឹងទន្លេសាប<br>- ស៊ីពពួកក្តាម កំពឹស រុក្ខជាតិបួងតុង និងសត្វល្អិត<br>- ប្រវែង ៣៥ ស.ម អាចបន្តពូជបាន ហើយបន្តពូជនៅពេលទឹកជំនឿង ក្នុងនាទីព្រៃលិចទឹក<br>- ប្រវែងវែងបំផុត ៤០ ស.ម ។ |
| ៥ |  | ត្រីតជ្រា | *Puntioplites bulu* | | | - រស់នៅស្រទាប់ទឹកពីកណ្តាលដល់បាត<br>- បម្លាស់ទីចូលក្នុងនាទីព្រៃលិចទឹកពេលទឹកឡើងខ្ពស់ និងត្រឡប់ចូលបឹងទន្លេសាបវិញនៅខែតុលា<br>- ស៊ីស្លែ ភរិរុក្ខជាតិ និងសត្វល្អិតជាអាហារ<br>- បន្តពូជក្នុងនាទីព្រៃលិចទឹកពេលទឹកជំនឿង<br>- ប្រវែងវែងបំផុត ៣៥ ស.ម ។ |
| ៦ |  | ផ្សោតក្បាលត្រឡោក | *Orcaella brevirostris* | Irrawaddy dolphin | | - រស់ និងបន្តពូជនៅក្នុងប្រព័ន្ធទន្លេ ចាប់ពីព្រំប្រទល់ប្រទេសឡាវ រហូតដល់ទីរួមខេត្តក្រចេះ ជួនកាលវាហែលតាមចាប់ចំណីរហូតដល់ខេត្តកំពង់ចាម និងកណ្តាល<br>- ចំណីរបស់វាគឺពពួកត្រីគ្រប់ប្រភេទ និងកំពឹស ជាប្រភេទចិញ្ចឹមកូននឹងទឹកដោះ ហើយអាចបន្តពូជចាប់ពីអាយុ ៧ ឆ្នាំ ដោយកូនម្តងក្នុងចន្លោះ ២ ឆ្នាំ ទំងន់ទើបនឹងកើតចន្លោះពី ១០ ទៅ ១២ គ.ក្រ ហើយទំងន់អតិបរមាប្រហែល ១៣០ គ.ក្រ<br>- អាយុកាលអតិបរមាប្រមាណ ៣០ ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៧ |  | ត្រីរាជ | *Pangasianodon gigas* | Mekong giant catfish | I | - ជាត្រីទឹកសាបធំបំផុត មានប្រវែងដល់ ៣០០ ស.ម<br>- បម្លាស់ទីចូលក្នុងបឹងទន្លេសាបនៅចន្លោះខែ ឧសភា ដល់កក្កដា និងត្រឡប់មកទន្លេមេគង្គវិញនៅចន្លោះខែតុលា ដល់ វិច្ឆិកា<br>- ស៊ីរុក្ខជាតិជាសំខាន់ និងសត្វល្អិតបន្ទាប់បន្សំ<br>- ពងកូនក្នុងអំឡុងខែមេសា-ឧសភា នៅប៉ែកទន្លេមេគង្គលើ តំបន់ទឹកជ្រៅ និងអន្លង់ជ្រៅៗ ។ |
| ៨ |  | ត្រីគល់រាំង | *Catlocarpio siamensis* | Giant barb | | - រស់តាមដងទន្លេធំៗ និងតំបន់ទំនាបទន្លេមេគង្គ<br>- ជាប្រភេទត្រីមានទំហំធំ រហូតដល់ ២០០ ស.ម និងបម្លាស់ទីឆ្ងាយ<br>- ស៊ីស្លែ រុក្ខជាតិ និងផ្លែរុក្ខជាតិលិចទឹក<br>- ពេញវ័យបន្តពូជអាយុ ៧ឆ្នាំ ហើយពងកូនចាប់ពីខែមិថុនា ដល់កក្កដា<br>- ប្រភេទត្រីនេះត្រូវបានកំណត់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ។ |
| ៩ |  | ត្រីត្រសក់ក្រហម | *Probarbus jullieni* | Isok barb | | - រស់នៅតំបន់ទន្លេមេគង្គ ចាប់ពីព្រំប្រទល់ប្រទេសឡាវ ដល់បឹងទន្លេសាប និងធ្វើចរាចរដូចត្រីរាជដែរ វាស៊ីពពួកខ្យង ខ្ចៅ និងកំពឹសជាអាហារ<br>- វាពងកូនគឺពីខែវិច្ឆិកា ដល់កុម្ភៈ តាមកន្លែងមានថ្មគ្រួស និងទឹកជ្រៅ ពិសេសនៅតាមដងទន្លេមេគង្គ និងទន្លេសេកុង<br>- ប្រវែងវែងបំផុត ១៥០ ស.ម ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ១០ |  | ត្រីត្រសក់ | *Probarbus labeamajor* | Thicklip barb | | - រស់ក្នុងអាងទន្លេមេគង្គលើ និងដៃទន្លេធំៗដែលមាន ថ្មនៅស្រទាប់បាត ពិសេសក្នុងទន្លេសេកុង<br>- វាស៊ីពពួកសត្វស្រទាប់បាត និងសត្វល្អិត<br>- រដូវពងកូនសំខាន់គឺចន្លោះខែវិច្ឆិកា ដល់កុម្ភៈ ហើយ ពងកូននៅតំបន់ដែលមានចរន្តទឹកហូរខ្លាំង<br>- ប្រវែងវែងបំផុត ១៥០ ស.ម ។ |
| ១១ |  | ត្រីត្រសក់ស | *Probarbus labeaminor* | Thinlip barb | | - រស់ក្នុងទន្លេធំៗ និងអាងទន្លេមេគង្គលើ ប៉ុន្តែកំរបាន ជួបក្នុងបឹងទន្លេសាបណាស់<br>- វាស៊ីពពួកសត្វស្រទាប់បាត និងសត្វល្អិត<br>- រដូវពងកូនសំខាន់គឺចន្លោះខែវិច្ឆិកា ដល់កុម្ភៈ<br>- ប្រវែងវែងបំផុត ៧០ ស.ម ។ |
| ១២ |  | អណ្តើកហ្លួង ឬសរសៃ | *Batagur baska* | Mangrove terrapin or estuarine terrapin | I | - រស់នៅតាមឆ្នេរខ្សាច់ តំបន់ព្រៃកោងកាង ឬ ទឹកសាប ពិសេសនៅតាមពាម<br>- ស៊ីចំរុះ (ស្លឹកឈើ ស្មៅ ផ្លែកោងកាង និងរុក្ខជាតិ នៅមាត់ទឹក និងពពួកខ្យងខ្ចៅ)<br>- បន្តពូជចាប់ពីខែកញ្ញា ដល់តុលា នៅតំបន់ទឹកជ្រៅ ហើយទំលាក់ពងពីខែមករា ដល់ចុងខែកុម្ភៈ ដោយ ពងបានពី ១៤ ទៅ ២០ គ្រាប់ពង ។ |
| **ក្រុមប្រភេទកំពុងរងគ្រោះ** | | | | | | |
| ១៣ |  | ត្រីត្រចៀកដំរី | *Osphronemus exodon* | Elephant ear gourami | | - រស់នៅតំបន់ទឹកហូរតិចៗ និងទឹកនឹង ដែលមាន រុក្ខជាតិលិចទឹកច្រើន ពិសេសក្នុងតំបន់ទន្លេមេគង្គនៃ ខេត្តក្រចេះ និងស្ទឹងត្រែង ហើយរស់នៅជាគូ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | - ស៊ីស្លែ និងពពួករុក្ខជាតិលិចទឹក<br>- ពងកូនចន្លោះខែមីនា ដល់មេសា ហើយអាចពងកូនម្តងទៀតពីខែសីហា ដល់តុលា<br>- ប្រវែងវែងបំផុត ៦០ ស.ម ។ |
| ១៤ |  | ត្រីរមាស | *Osphronemus goramy* | Giant gourami | | - រស់នៅតំបន់ទន្លេមេគង្គលើ ចាប់ពីល្បាក់ខោន ដល់ខេត្តស្ទឹងត្រែង និងមានជួបប្រទះផងដែរនៅខេត្តក្រចេះ ដោយរស់ជាគូ ឬ ជាហ្វូង<br>- ស៊ីកំទេចកំទីរុក្ខជាតិ ដូចជាស្លឹក ផ្លែ និងផ្កា សត្វល្អិត ពពួកក្តាម និងកំពឹស<br>- ពងកូននៅរដូវប្រាំង ជាប្រភេទពងអណ្តែត ហើយញាស់ក្នុងរយៈពេល ៣៦ ម៉ោង នៅសីតុណ្ហភាព ២៥-៣០ អង្សាសេ<br>- ប្រវែងវែងបំផុត ៦០ ស.ម ។ |
| ១៥ |  | ត្រីកន្ទ្រប់ខ្លា | *Datnioides undecimradiatus* | Narrow barred tigerperch | | - រស់នៅតាមស្ទឹង បឹងបួរ និងអាងទឹក ពិសេសក្នុងនាទីព្រៃលិចទឹក<br>- វាស៊ីត្រី កូនសត្វល្អិត ក្តាម កំពឹស និងជន្លេន<br>- ពងកូនពីខែកុម្ភៈ ដល់មីនា ជាប្រភេទពងអណ្តែត ប្រវែងវែងបំផុត ៤០ ស.ម ។ |
| ១៦ |  | ត្រីក្បក | *Tenualosa thibaudeaui* | Laotian shad | | រស់នៅតំបន់ទន្លេមេគង្គ និងតំបន់បឹងទន្លេសាប ជាប្រភេទធ្វើចរាចរឆ្ងាយ ហើយធ្វើចរាចរពីទន្លេចូលទៅបឹងទន្លេសាបពីខែឧសភា ដល់សីហា ហើយត្រឡប់វិញនៅខែតុលា ឬ វិច្ឆិកា<br>- [illegible] |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | - ពងកូននៅតំបន់បឹងទន្លេសាបចាប់ពីខែធ្នូ ដល់មករា<br>- ប្រវែងវែងបំផុត ៣០ ស.ម ។ |
| ១៧ |  | ត្រីកញ្ចុះក្របី | *Glyptothorax fuscus* | | | - រស់ក្នុងតំបន់ថ្ម ឬ គល់ឈើនៃទន្លេដែលមានចរន្តទឹកហូរខ្លាំងបង្គួរ ពិសេសក្នុងខេត្តក្រចេះ និងស្ទឹងត្រែង<br>- ស៊ីប្រភេទសត្វល្អិត១<br>- រដូវពងកូនអាចចន្លោះពីខែឧសភា ដល់មិថុនា<br>- ប្រវែងវែងបំផុត ១២ ស.ម ។ |
| ១៨ |  | ត្រីស្ទូក | *Wallago leeri* | | | - រស់នៅតំបន់មេគង្គលើ ជាពិសេសតាមដងទន្លេសេសាន និងស្រែពក<br>- ជាប្រភេទធ្វើចរាចរជិត<br>- ស៊ីត្រី និងកំពីសជាអាហារ<br>- ពងកូននៅចន្លោះខែមេសា ដល់តុលា ហើយភាគច្រើនគឺនៅក្នុងខែមិថុនា ដោយទំលាក់ពងនៅពេលយប់ក្នុងតំបន់វាលស្មៅលិចទឹក<br>- ប្រវែងវែងបំផុត ១៨០ ស.ម ។ |
| ១៩ |  | អណ្តើកសង្កល់ | *Heosemys annandalii* | Yellow-headed temple turtle | | - មាននៅតំបន់ទំនាប ពិសេសបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេស្រែពក (វាលភក់ ស្រះ តំបន់ទឹកនឹង ឬ តំបន់ទឹកហូរតិច១)<br>- ស៊ីរុក្ខជាតិអណ្តែតទឹក (ព្រលិត ត្រកួន..) ។ |
| ២០ |  | អណ្តើកក្អែក | *Siebenrockiella crassicollis* | Black marsh turtle | | - រស់ក្នុងតំបន់ទឹកសាប ដែលមានចរន្តទឹកហូរ តិច១ ឬទឹកនឹង (ស្រះ ព្រៃក និងវាលភក់)<br>- ស៊ីអាហារចំរុះ រួមមាន វារីសត្វឥតឆ្អឹងកង |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | សាច់រលួយ និងវារីរុក្ខជាតិ<br>- រដូវបន្តពូជពីខែមេសា ដល់កក្កដា ។ |
| **ក្រុមប្រភេទងាយរងគ្រោះ** | | | | | | |
| ២១ |  | ត្រីក្របី | *Bagarius bagarius* | Dwarf goonch | | - រស់ក្នុងតំបន់ទឹកជ្រៅ និងមានថ្មនៃទន្លេមេគង្គ ពិសេសក្នុងខេត្តស្ទឹងត្រែង និងក្រចេះ<br>- ជាប្រភេទរស់នៅស្រទាប់បាត ស៊ីពពួកសត្វល្អិត កំពឹស ក្តាម និងត្រីល្អិតជាអាហារ<br>- ពងកូនចន្លោះខែមិថុនា ដល់កក្កដា នៅតាមមាត់ស្ទឹងដែលតភ្ជាប់ពីទន្លេធំៗ<br>- ប្រវែងវែងបំផុត ២៥ ស.ម ។ |
| ២២ |  | ត្រីក្របី | *Bagarius suchus* | Crocodile catfish | | - ប្រទះឃើញក្នុងទន្លេធំៗនៃអាងទន្លេមេគង្គ តាមបណ្តោយព្រំប្រទល់ថៃ ឡាវ និងទន្លេភាគខាងជើងនៃប្រទេសកម្ពុជា<br>- ជាប្រភេទមិនធ្វើចរាចរ រស់នៅស្រទាប់បាត ស៊ីពពួកសត្វល្អិត កំពឹស បង្កង និងត្រីជាអាហារ<br>- ពងកូនក្នុងខែកក្កដា នៅតាមមាត់ស្ទឹងដែលតភ្ជាប់ទៅទន្លេធំៗ<br>- ប្រវែងវែងបំផុត ៧០ ស.ម ។ |
| ២៣ |  | ត្រីក្របី | *Bagarius yarrelli* | Goonch | | - រស់ក្នុងទន្លេមេគង្គលើ តំបន់ទឹកជ្រៅ និងមានថ្មច្រើន<br>- ជាពពួករស់នៅស្រទាប់បាត ស៊ីពពួសត្វល្អិត កំពឹស កង្កែប ជន្លេន និងត្រីជាអាហារ<br>- ពងកូនក្នុងទន្លេ ពិសេសមុនពេលទឹកជំនន់ឡើង<br>- ប្រវែងវែងបំផុត ៣៥ ស.ម ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ២៤ |  | ត្រីឆ្មាក្រពើ | *Lycothrissa crocodilus* | Sabertooth thryssa | | - រស់នៅតំបន់ទឹកភ្លាវ ហើយជារឿយៗហែលឡើងទៅតំបន់ទឹកសាប<br>- ជួបប្រទះនៅផ្នែកខាងក្រោមល្បាក់ខោន រហូតដល់តំបន់ដីសណ្តទន្លេមេគង្គ ទន្លេសាប និងបឹងទន្លេសាប ហើយពេលខ្លះរស់ក្នុងអន្លង់ជ្រៅៗនៃទន្លេមេគង្គ<br>- ស៊ីពពួកសត្វល្អិត ក្តាម កំពឹស និងត្រីតូចៗ<br>- រដូវពងកូនគឺនៅចុងរដូវប្រាំង និងដើមរដូវវស្សា ពិសេស ចន្លោះខែមីនា ដល់មេសា<br>- ប្រវែងវែងបំផុត ៣០ ស.ម ។ |
| ២៥ |  | ក្រពើត្រី | *Crocodylus siamensis* | Siamese crocodile | I | - រស់ក្នុងតំបន់ទឹកសាប ដូចជាទន្លេ ដៃទន្លេ បឹង និងព្រៃកតាមជួរភ្នំ<br>- ជាប្រភេទស៊ីសាច់ជាអាហារ ពិសេសត្រី<br>- អាយុពី ៧ ឆ្នាំ អាចបន្តពូជបាន ដោយបន្តពូជចាប់ពីខែវិច្ឆិកា ដល់ឧសភា ហើយទំលាក់ពងចន្លោះពី ២០ ទៅ ៦០ គ្រាប់/ក្រពើមេ ១ ក្បាល ។ |
| ២៦ |  | អណ្តើកស្រែ | *Malayemys subtrijuga* | Rice-field terrapin | | - រស់ក្នុងទីតាំងមានចន្លទឹកហូរតិចៗ និងតាមវាលស្រែ<br>- ស៊ីខ្យងសត្វ ដង្កូវ សត្វល្អិតក្នុងទឹក និងត្រីតូចៗ<br>- ទំលាក់ពងពី ៦ ទៅ ៨ ប៉ុណ្ណោះ ហើយញាស់ក្នុងរយៈពេល ១៦៧ ថ្ងៃ នៅសីតុណ្ហភាពចន្លោះពី ២៨ ទៅ ៣០ អង្សាសេ<br>- អាយុពេញវ័យបន្តពូជគឺ ៣ ឆ្នាំ ចំពោះឈ្មោល និង ៥ ឆ្នាំចំពោះញី ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ២៧ |  | អណ្តើកសោម | *Heosemys grandis* | Asian giant terrapin | II | - រស់នៅភាគច្រើនក្នុងតំបន់ទឹកសាប<br>- ស៊ីអាហារចំរុះ (ផ្លែឈើ រុក្ខជាតិ និងសាច់)<br>- ទំលាក់ពងម្តង១ពី ៤ ទៅ ៥ គ្រាប់/មេមួយក្បាល ។ |
| ២៨ |  | កន្ធាយអាស៊ី | *Amyda cartilaginea* | Asiatic soft –shell turtle | II | - រស់ក្នុងតំបន់ទឹកសាប តែពងនៅលើច្រាំងខ្សាច់<br>- ស៊ីអាហារចំរុះ (សត្វល្អិត ក្តាម កំពឹស ខ្យង ត្រី សាច់រលួយ ផ្លែឈើ គ្រាប់ពូជរុក្ខជាតិ)<br>- រួមភេទក្នុងទឹក និងទំលាក់ពងពី ៣ ទៅ ៣០ គ្រាប់/មេមួយក្បាល ។ |
| ២៩ |  | កន្ធាយក្បាលកង្កែប | *Pelochelys cantorii* | Asian giant soft-shell turtle | II | - ទើបតែរកឃើញជាថ្មីនៅតាមបណ្តោយទន្លេមេគង្គក្នុងប្រទេសកម្ពុជា<br>- រស់នៅក្នុងអន្លង់ទឹកជ្រៅជាង ៤០ ម<br>- ស៊ីត្រី រុក្ខជាតិដុះក្នុងទឹក ក្តាម កំពឹស ។ល។<br>- បន្តពូជក្នុងខែកុម្ភៈ និងមីនា ហើយទំលាក់ពងពី ២៨ ទៅ ៣០ គ្រាប់/មេមួយក្បាល<br>- ទំងន់អតិបរមា ៥០ គ.ក្រ និងប្រវែង ២ ម ។ |
| **ខ.សមុទ្រ**<br>**ក្រុមប្រភេទជិតផុតពូជ** | | | | | | |
| ៣០ |  | ក្រពើសមុទ្រ | *Crocodylus porosus* | Estuarine crocodile | I | - ភាគច្រើនរស់នៅតាមតំបន់ឆ្នេរ ឬ តាមពាម តំបន់ព្រៃកោងកាង និងតំបន់វាលភក់<br>- ស៊ីសាច់ជាអាហារ ដូចជាក្តាមថ្ម អណ្តើក ពស់ សត្វស្លាប ស្វា ជ្រូក ។ល។<br>- បន្តពូជនៅរដូវវស្សា<br>- អាយុបន្តពូជពី ១០-១២ ឆ្នាំ ចំពោះក្រពើញី និង |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ១៦ ឆ្នាំ ចំពោះក្រពើឈ្មោល<br>- ក្រពើញីអាចទំលាក់ពងពី ៤០-៩០ គ្រាប់។ |
| ៣១ |  | ជ្រូកទឹក ឬ ពយ៉ុង | *Dugong dugon* | Dugong | I | - រស់ក្នុងតំបន់ស្មៅសមុទ្រ ពិសេសក្នុងខេត្តកំពត ដែលមានជម្រៅរាក់ជាង ១០ ម.<br>- ស៊ីស្មៅសមុទ្រជាអាហារ ដោយពេលពេញវ័យស៊ី ៣០ គ.ក្រ/ថ្ងៃ និងស៊ីសត្វឥតឆ្អឹងកងផងដែរ<br>- វដ្តបន្តពូជកើតមានពេញមួយឆ្នាំ ហើយពេញវ័យបន្តពូជនៅចន្លោះ ១០-១៧ ឆ្នាំ ដោយកើតកូនបាន ១ក្បាល រៀងរាល់ ៣ ទៅ ៧ ឆ្នាំ ម្តង<br>- ពពោះចន្លោះពី ១២ ទៅ ១៤ខែ ហើយទំងន់កូនទើបនឹងកើតពី ២៥ ទៅ ៣៥ គ.ក្រ<br>- ជ្រូកទឹកពេញវ័យមានទំងន់ដល់ ១.០០០ គ.ក្រ។ |
| **ក្រុមប្រភេទកំពុងរងគ្រោះ** | | | | | | |
| ៣២ |  | ត្រីសេកបូក | *Cheilinus undulates* | Humphead Wrasse | II | - ពេលតូចរស់នៅតំបន់ស្មៅសមុទ្រ និងព្រៃកោងកាងក្បែរតំបន់ផ្កាថ្ម (ទឹករាក់) ហើយពេលធំរស់នៅក្រៅតំបន់ផ្កាថ្ម (ទឹកជ្រៅជាង)<br>ជាត្រីប្លូរភេទ និងស៊ីកាំប្រមាសមុទ្រ សត្វវល្លជាតិ ត្រីសិប្បិជាតិ និងសត្វឥតឆ្អឹងកង<br>ពេញវ័យបន្តពូជចាប់ពីអាយុ ៨ ឆ្នាំឡើងទៅ និងពងកូននៅក្នុងតំបន់ផ្កាថ្ម។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៣៣ |  | បាឡែនក្របី | *Pseudorca crassidens* | False killer whale | II | - មានរស់នៅក្បែរកោះរុងសន្លឹម<br>- ស៊ីត្រី មឹក បង្គា និងពពួកថនិកសត្វទឹក<br>- ពេញវ័យបន្តពូជចាប់ពីអាយុ ៨-១១ ឆ្នាំ<br>- ទំងន់អតិបរមាប្រហែល ១.៣៦០ គ.ក្រ ហើយអាយុអតិបរមា ៥៨-៦៣ ឆ្នាំ។ |
| ៣៤ |  | បាឡែនក្បាលធំ | *Globicephala macrorhynchus* | Short-finned pilot whale | II | - ប្រទះឃើញក្នុងតំបន់ឆ្នេរខេត្តកែប<br>- ចូលចិត្តរកចំណីពេលយប់ និងពេលព្រលឹម ដោយស៊ីត្រី និងមឹកក្នុងបរិមាណ ៤៥ គ.ក្រ /ថ្ងៃ<br>- វាបន្តពូជជាក្រុមក្នុងអាត្រាញី ៨ ឈ្មោល ១<br>- អាយុពេញវ័យបន្តពូជពី ៧-២២ ឆ្នាំ<br>- វាបន្តពូជពេញ ១ ឆ្នាំ ពពោះពី ១១- ១៣ ខែ ហើយកូនម្តងបាន ១ ក្បាល<br>- ក្នុងចន្លោះ ៧ ឆ្នាំ ទើបវាមានកូនម្តង ហើយក្នុងមួយជីវិតបាឡែនមានកូនតែ ៤-៥ ក្បាល។ |
| ៣៥ |  | ផ្សោតច្រមុះដបចំពុះខ្លី | *Tursiops aduncus* | Indo-Pacific bottlenose dolphin | | - រស់ក្បែរកោះរុង កោះរុងសន្លឹម និងកោះតាង<br>- ស៊ីពពួកត្រី មឹក និងបង្គា<br>- បន្តពូជនៅចុងនិទាឃរដូវ និងដើមរដូវក្តៅ ពពោះក្នុងរយៈពេល ១២ ខែ ហើយកូនផ្តាច់ដោះរយៈពេលចន្លោះពី ១៨ ទៅ ២៤ ខែ<br>- ទំងន់ទើបនឹងកើតចន្លោះពី ៩ ទៅ ២១ គ.ក្រ ហើយទំងន់អតិបរមា ២៣០ គ.ក្រ ចំពោះឈ្មោល និង ១៨០ គ.ក្រ ចំពោះញី<br>- អាយុកាលអតិបរមា ៤០ ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៣៦ |  | ផ្សោតក្បាលត្រឡោក | *Orcaella brevirostris* | Irrawaddy dolphin | I | - រស់នៅស្ទើរគ្រប់ទឹកខ្លែងតាមបណ្តោយទន្លេ<br>- ស៊ីត្រីគ្រប់ប្រភេទ បង្គា និងមឹក<br>- ទំងន់ទើបនឹងកើតចន្លោះពី ១០ ទៅ ១២ គ.ក្រ<br>- អាយុអតិបរមាប្រមាណ ៣០ ឆ្នាំ ហើយទំងន់អតិបរមាជាង ១៣០ គ.ក្រ។ |
| ៣៧ |  | ផ្សោតច្រមុះដបចំពុះ វែង | *Tursiops truncatus* | Common bottlenose dolphin | II | - រស់នៅក្បែរកោះរុង កោះរុងសន្លឹម និងកោះតាង<br>- ស៊ីពពួកត្រីគ្រប់ប្រភេទ និងបង្គា<br>- ពពោះក្នុងរយៈពេល ១២ ខែ ហើយកូនផ្តាច់ដោះចន្លោះពី ១៨ ទៅ ២០ ខែ<br>- ទំងន់ទើបនឹងកើតចន្លោះ ១៤ ទៅ ២០ គ.ក្រ ហើយទំងន់អតិបរមា ៥០០ គ.ក្រ ចំពោះភេទឈ្មោល និង ២៦០ គ.ក្រ ចំពោះភេទញី<br>- អាយុអតិបរមា ៤០ ទៅ ៤៥ ឆ្នាំចំពោះឈ្មោល និងយ៉ាងតិច ៥០ ឆ្នាំ ចំពោះញី។ |
| ៣៨ |  | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacific hump-backed dolphin | | - រស់នៅតាមបណ្តោយឆ្នេរ មាត់ពាម និងក្បែរព្រៃកោងកាងក្នុងឃុំថ្មស ខេត្តកោះកុង<br>- ស៊ីពពួកត្រី បង្គា និងមឹក<br>- ពពោះរយៈពេលពី ១០ ទៅ ១២ ខែ ទើបកើត ហើយចិញ្ចឹមកូនដោយទឹកដោះរយៈពេល ២ ឆ្នាំ ទំងន់ទើបនឹងកើត ១៤ គ.ក្រ ហើយទំងន់អតិបរមា ២៦០ គ.ក្រ ចំពោះភេទឈ្មោល និង ១៧០ គ.ក្រ ចំពោះភេទញី<br>- អាយុអតិបរមាយ៉ាងតិច ៤០ ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៣៩ |  | ផ្សោតឆ្នូតភ្នែក | *Stenella longirostris roseinventris* | Dwarf spinner dolphin | II | - មានរស់នៅក្បែរកោះតាង<br>- ស៊ីពពួកត្រី បង្គា និងមឹក<br>- មេពពោះក្នុងរយៈពេលប្រហែល ១០ ខែ កន្លះ ទើបកើត ហើយចិញ្ចឹមកូនដោយទឹកដោះក្នុងចន្លោះពេលពី ១ ឆ្នាំ ទៅ ២ ឆ្នាំ។ |
| ៤០ |  | ផ្សោតអុច | *Stenella attenuata* | Pantropical spotted dolphin | II | - មានរស់នៅក្បែរកោះតាង និងកោះប៉ូឡូវ៉ៃ<br>- ស៊ីត្រី មឹក ក្តាម និងបង្គា<br>- អាចផ្តល់កំណើតជាកូនផ្សោតគ្រប់ពេលវេលា<br>- ពពោះក្នុងរយៈពេលប្រហែលជាង ១១ ខែ<br>- មេផ្តល់ទឹកដោះដល់កូនក្នុងរយៈពេលយ៉ាងតិចបំផុត ១ ឆ្នាំ និងយ៉ាងយូរបំផុត ២ ឆ្នាំ<br>- អាយុកាលអតិបរមា ៤០ ឆ្នាំ ចំពោះឈ្មោល និង ៤៦ ឆ្នាំ ចំពោះញី។ |
| ៤១ |  | ផ្សោតឥតព្រុយខ្នង | *Neophocaena phocaenoides* | Finless porpoise | | - រស់នៅក្បែរឆកកំពង់សោម និងតាមបណ្តោយឆ្នេរនៃខេត្តកោះកុង និងកែប<br>- ស៊ីត្រី មឹក ក្តាម និងបង្គាជាអាហារ<br>- ផ្តល់កំណើតនៅនិទាឃរដូវ និងដើមរដូវក្តៅ ពពោះក្នុងរយៈពេលយ៉ាងតិច ១១ ខែ មេផ្តល់ទឹកដោះដល់កូនក្នុងរយៈពេល ៧ ខែ ទំងន់ទើបនឹងកើតប្រមាណ ៦ គ.ក្រ ហើយទំងន់អតិបរមា ៧.២ គ.ក្រ<br>- អាយុកាលអតិបរមាយ៉ាងតិច ៣៣ ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៤២ |  | ផ្សោតខ្មៅលឿង | *Dolphinus capensis tropicalis* | Long-beaked common dolphin | I | - រស់នៅក្បែរកោះរុង និងកោះរុងសន្លឹម<br>- ចំណីរបស់វារួមមានត្រីតូចៗ និងមឹក<br>- ពពោះក្នុងរយៈពេលយ៉ាងតិច ១១ ខែ ហើយមេផ្តល់ទឹកដោះក្នុងរយៈពេលយ៉ាងតិច ១០ ខែ<br>- អាយុកាលអតិបរមាប្រហែល ៤០ ឆ្នាំ។ |
| ៤៣ |  | ល្មិច | *Chelonia mydas* | Green turtle | I | - រស់នៅតាមតំបន់ឆ្នេរ ជាពិសេសនៅតំបន់ខ្សាច់ដែលមានស្មៅសមុទ្រ និងសារាយ<br>- ស៊ីរុក្ខជាតិដូចជាស្មៅសមុទ្រ និងសារាយ<br>- ឡើងមកពងកូននៅតាមកោះដែលមានខ្សាច់ និងដាច់ស្រយាលពីមនុស្ស ចាប់ពីម៉ោង ១១ យប់ក្នុងខែពេញបូណ៌មី។ |
| ៤៤ |  | ក្រាស | *Eretmochelys imbricata* | Hawksbill turtle | I | - រស់តាមតំបន់ផ្កាថ្ម និងធ្វើសំបុកនៅតាមឆ្នេរខ្សាច់ និងនៅតាមកោះដែលមានសភាពស្ងប់ស្ងាត់<br>- ស៊ីចំរុះ (ស្លង់ ខ្ទៅសមុទ្រ សិប្បិសត្វ សារាយ)<br>- វាពេញវ័យបន្តពូជពីអាយុ ៣០ ឆ្នាំឡើងទៅ ហើយរយៈពេលពី ២-៣ ឆ្នាំ ទើបពងម្តង។ |
| ៤៥ |  | ល្មិចព្រុយបី ឬ ល្មិចស្តី | *Dermochelys coriacea* | Leatherback turtle | I | - រស់ក្នុងកន្លែងទឹកជ្រៅ ហើយចូលមករកចំណីនៅកន្លែងទឹករាក់<br>- ស៊ីខ្ទៅសមុទ្រ និងសត្វសមុទ្រ<br>- ពងកូននៅតាមតំបន់ឆ្នេរដាច់ស្រយាលពីមនុស្ស និងមានសភាពស្ងប់ស្ងាត់។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៤៦ |  | ល្មិចក្បាលធំ | *Caretta caretta* | Loggerhead turtle | I | - រស់នៅតាមតំបន់ឆ្នេរ ហើយកូនរបស់វាចូលចិត្តរស់នៅតាមតំបន់ដែលមានរុក្ខជាតិអណ្តែតទឹក<br>- ស៊ីសាច់ជាអាហារ ពិសេសសត្វស្រទាប់បាត ដូចជាសិប្បិសត្វ ក្តាម ត្រី និងខ្ញែរសមុទ្រ<br>- វាពេញវ័យបន្តពូជចាប់ពីអាយុ ៣០ ឆ្នាំ ឡើងទៅ ហើយវាពងកូនក្នុងរយៈពេល ២ ឆ្នាំម្តង។ |
| ៤៧ |  | ល្មិចប្រផេះ | *Lepidochelys olivacea* | Olive ridley turtle | I | - រស់នៅតាមតំបន់ឆ្នេរ និងសមុទ្រក្រៅដែលមានជម្រៅទឹកជ្រៅ ហើយចូលមកពងនៅតាមតំបន់ឆ្នេរដែលឆ្ងាយពីមនុស្ស និងមានភាពស្ងប់ស្ងាត់<br>- ស៊ីអាហារចំរុះ ដូចជាក្តាម បង្កង សិប្បិសត្វ សារាយ និងខ្ញែរសមុទ្រ<br>- វាពេញវ័យបន្តពូជពីអាយុ ១៧ ឆ្នាំ ឡើងទៅ ហើយពងកូនក្នុងរយៈពេល ២ ឬ ៣ ឆ្នាំម្តង។ |
| ៤៨ |  | គ្រុំយក្ស | *Tridacna squamosa* | Fluted giant clam | | - មានសំបកអតិបរមាប្រវែង ៤០ ស.ម<br>- រស់នៅក្នុងជម្រៅទឹកមិនលើសពី ២០ ម ដោយភ្ជាប់ខ្លួនរបស់វាទៅនឹងផ្កាថ្ម<br>- ជាប្រភេទស៊ីច្រោះ និងស្រូបយកសារធាតុសរីរាង្គដែលរលាយក្នុងទឹក<br>បន្តពូជនៅរដូវវស្សា<br>ពេលពេញវ័យបន្តពូជ វាមានភេទឈ្មោល ហើយ ១ ឆ្នាំក្រោយមកវាមានភេទញី ដោយមានសរីរាង្គបន្តពូជញីផងឈ្មោលផង<br>- ជាទូទៅវាបញ្ចេញស្ពែមមុនទើបបញ្ចេញពង។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៤៩ |  | គ្រុំយក្ស | *Tridacna maxima* | Elongate giant clam | II | - មានសំបកអតិបរមាប្រវែង ៣៥ ស.ម<br>- រស់នៅក្នុងជម្រៅទឹកមិនលើសពី ២០ម ដោយភ្ជាប់ខ្លួនទៅនឹងថ្ម ឬ ផ្កាថ្ម<br>- វាច្រោះយកបួងតុងរុក្ខជាតិជាអាហារ និងស្រូបយកអុកស៊ីសែនតាមស្រកី<br>- ពេលពេញវ័យបន្តពូជ វាមានភេទឈ្មោល ហើយពី ២-៣ ឆ្នាំក្រោយក្លាយជាខ្មី<br>- ជាទូទៅ វាបញ្ចេញស្ពែមមុនទើបបញ្ចេញពង។ |
| ៥០ |  | គ្រុំយក្ស | *Tridacna crocea* | Crocus giant clam | II | - ជាគ្រុំយក្សតូចជាងគេបំផុត ត្រឹមតែ ១៥ ស.ម<br>- ខ្លួនរបស់វាទាំងមូលកប់ចូលទៅក្នុងផ្កាថ្ម<br>- រស់នៅក្នុងជម្រៅទឹកមិនលើសពី ២០ ម នៅតំបន់ផ្កាថ្មជំរាល<br>- ពេញវ័យបន្តពូជនៅអាយុពី ៧-៨ ឆ្នាំ ដោយពងកូននៅខែកញ្ញា ដល់ធ្នូ<br>- ជាប្រភេទគ្រុំដែលមានការលូតលាស់យឺតជាងគេ។ |
| ៥១ |  | គ្រុំយក្ស | *Tridacna gigas* | Giant clam | | - សំបកអតិបរមារហូតដល់ ១៣៧ ស.ម<br>- រស់នៅក្នុងតំបន់ដែលមានចរន្តទឹកខ្សោយ ជំរៅមិនលើសពី ២០ ម ពិសេសនៅតំបន់ផ្កាថ្ម<br>- អាហារសំខាន់គឺពឹងលើការធ្វើរស្មីសំយោគ វាក៏ស៊ីច្រោះបួងតុងរុក្ខជាតិ និងអាហារតូចៗដែរ<br>- បន្តពូជដោយបញ្ចេញទឹកកាម និងពងនៅក្នុងសមុទ្រ ភាគច្រើនពងកូននៅខែតុលា ដល់កុម្ភៈ<br>- មានអាយុវែងរហូតដល់ ៤០ ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៥២ |  | ខ្យងកោដ្ឋ | *Trochus niloticus* | Commercial top | | - រស់នៅតំបន់ផ្កាថ្មដែលមានជំរៅទឹករាក់<br>- វាស៊ីសារាយដែលមានសសៃឆ្មារ១<br>- ពេញវ័យមានទំហំ ពី ១១ - ១៥ ស.ម<br>- ពេញវ័យច្រើនរស់នៅក្នុងជំរៅទឹកលើស ពី ១០ ម។ |
| ៥៣ |  | ខ្យងគុជ ឬ ខ្យង ប្រាក់ | *Turbo marmoratus* | Green turbo or green snail | | - ពេលតូចរស់នៅក្នុងតំបន់ផ្កាថ្ម ដែលមានជំរៅទឹកពី ១ ទៅ ៥ ម និងពេលពេញវ័យរស់នៅក្នុងតំបន់ទឹកជ្រៅចាប់ពី ២០ ម<br>- មានទំហំសំបករហូតដល់ ២២ ស.ម។ |
| ៥៤ |  | សេះសមុទ្រ ( ត្រី) | *Hippocampus* spp. | Sea horse | II | - រស់នៅតំបន់ស្មៅសមុទ្រ ល្បាប់ខ្សាច់ ដែលសមុទ្រ ពិសេសនៅជុំវិញកោះរុង និងរុងសន្លឹម<br>- វាស៊ីបង្កងសត្វ សត្វវល្លជាតិតូច១ និងកូនត្រី<br>- អាយុ ១៤ សប្តាហ៍អាចបន្តពូជបាន<br>- វាបន្តពូជរៀងរាល់ ២០-២៨ ថ្ងៃ ពេញមួយឆ្នាំ<br>- សេះសមុទ្រឈ្មោលជាអ្នកពពោះ ហើយរយៈពេល ២០ ដល់ ២៨ ថ្ងៃ ទើបញាស់<br>- ជាទូទៅ ក្នុងពេលមានគភ៌ម្តង១ សេះសមុទ្រឈ្មោល កើតបានកូន ១០០-២០០ ក្បាល។ |
| ៥៥ |  | ផ្កាថ្ម | *Anthozoa spp.* | Corals and sea anemones | | - ដុះជុំវិញកោះ ចាប់ពីច្រាំង ដល់ជម្រៅ ៣ ត.ម ភាគច្រើនដុះនៅជុំវិញកោះរុង កោះរុងសន្លឹម កោះស្តេច និងកោះផ្សេង១ទៀត<br>- មានចំនួនសរុបប្រមាណ ២.៨០០ ហិកតា ជាង ៧០ ប្រភេទ ចែកជា ២ក្រុម ( ផ្កាថ្មរឹង និងទន់)<br>- អាចលូតលាស់ប្រមាណ ១-២ ស.ម/ឆ្នាំ។ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៥៦ |  | ប្រឡាំងកាស | *Tachypleus gigas* | Traingular-tail horseshoe crab | | - រស់ក្នុងលំហសមុទ្រ ហើយបម្លាស់ទីមកតំបន់ឆ្នេរដើម្បីធ្វើសំបុកពងកូន<br>- វាស៊ីមឹក បង្គា និងត្រីជាអាហារ<br>- ញីពេញវ័យបន្តពូជចាប់ពីស្នូកប្រវែង ៥៨ ម.ម និងឈ្មោលមានប្រវែង ១១១ ម.ម<br>- ឈ្មោលសក ១២ ដង និងញីសក ១៣ ដង ទើបពេញវ័យបន្តពូជ<br>- សកម្មភាពបន្តពូជមានពេញមួយឆ្នាំ។ |
| ៥៧ |  | កាចរ | *Carcinoscorpius rotundicauda* | Mangrove horseshoe crab | | - មានប្រវែងរហូតដល់ ៤០ ស.ម (ទាំងកន្ទុយ)<br>- ស៊ីដង្កូវ និងសិប្បិជាតិជាសំខាន់<br>- អាចទំលាក់ពងពី ៦០.០០០-១២០.០០០គ្រាប់ នៅលើខ្សាច់ និងញាស់ក្រោយ ២ សប្តាហ៍<br>- វាពេញវ័យបន្តពូជចាប់ពីអាយុ ១១ ឆ្នាំ។ |
| ៥៨ |  | ត្រីបាឡេនតីង្គក់ | *Rhincodon typus* | Whale shark | II | - ភាគច្រើនរស់នៅក្នុងតំបន់ទឹកជ្រៅ<br>- វាស៊ីកូនបង្គា (គី) មឹក និងកូនត្រី<br>- ពេញវ័យបន្តពូជពេលមានប្រវែងលើសពី ៦ ម<br>- វាមានអាយុវែងបំផុតពី ១០០-១៥០ ឆ្នាំ។ |

បានបញ្ឈប់បញ្ជីនេះត្រឹមលេខរៀង ៥៨។

Downloaded from http://www.khmerlaws.com